**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២៦៥.១៤.អជរ.លចរ

# សារាចរ
# ស្តីពី
# ទម្រង់ និងបែបបទរៀបចំ
# គម្រោងផែនការអាជីវកម្មរ៉ែសំណង់

ក្រសួងរ៉ែនិងថាមពល មានតួនាទីដឹកនាំយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍន៍ និងអាជីវកម្មរ៉ែសំណង់ប្រកបដោយការទទួលខុសត្រូវ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជនកម្ពុជាគ្រប់រូប។

ការអភិវឌ្ឍន៍ និងអាជីវកម្មរ៉ែសំណង់ ប្រកបដោយការទទួលខុសត្រូវ មានន័យថា ប្រតិបត្តិការរ៉ែសំណង់ទាំងអស់ ត្រូវបានអនុវត្តស្របតាមបទដ្ឋាន និងទម្លាប់អនុវត្តន៍ល្អប្រសើរនៃស្តង់ដារសុវត្ថិភាព បរិស្ថាន និងសង្គម ចាប់តាំងពីដំណាក់កាលរៀបចំផែនការ ប្រតិបត្តិការអាជីវកម្ម ការបញ្ចប់អាជីវកម្ម និងការស្តារបរិស្ថានឡើងវិញ។

ស្របតាមច្បាប់ស្តីពី ការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ក្នុងគោលដៅពិនិត្យវាយតម្លៃលក្ខណៈសេដ្ឋកិច្ច និងសង្គមនៃគម្រោងប្រតិបត្តិការរ៉ែសំណង់ មុនការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ក្រសួងរ៉ែនិងថាមពល តម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណរ៉ែសំណង់ទាំងអស់ រៀបចំ និងដាក់ជូនក្រសួងពិនិត្យនូវឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ស្របតាមការកំណត់ក្នុងសារាចរនេះ។

អាស្រ័យលើទំហំ ទ្រង់ទ្រាយសកម្មភាព និងបច្ចេកទេសនៃការធ្វើអាជីវកម្ម ក្រសួងរ៉ែនិងថាមពល អាចតម្រូវលក្ខខណ្ឌបន្ថែម ឬ បន្ធូរបន្ថយលក្ខខណ្ឌ មាតិកា និងឯកសារ តម្រូវក្នុងការរៀបចំគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ស្របតាមសារាចរនេះ។

## ១. គោលបំណងនៃសារាចរនេះ

សារាចរនេះមានគោលបំណង៖

- ណែនាំការរៀបចំ និងទម្រង់នៃឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ដែលត្រូវភ្ជាប់ជាមួយនឹងសំណុំលិខិតស្នើសុំអាជ្ញាបណ្ណធនធានរ៉ែ
- កំណត់នីតិវិធី និងដំណើរការពិនិត្យវាយតម្លៃឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់
- ជំរុញតម្លាភាព និងផ្តល់ជំនួយដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធនធានរ៉ែក្នុងការអនុលោមតាមបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការរៀបចំ និងដាក់ជូនក្រសួងពិនិត្យនូវឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់។

## ២. គោលការណ៍នៃការអភិវឌ្ឍន៍ និងអាជីវកម្មរ៉ែសំណង់ ប្រកបដោយការទទួលខុសត្រូវ

ក្រសួងរ៉ែនិងថាមពល ជំរុញការអនុលោមតាមគោលការណ៍នៃការអភិវឌ្ឍន៍ និងអាជីវកម្មរ៉ែសំណង់ ប្រកបដោយការទទួលខុសត្រូវ ដែលកំណត់ដោយស្ថាប័ន ក្រុមប្រឹក្សាអន្តរជាតិស្តីពីអាជីវកម្មរ៉ែ និងលោហៈ (International Council on Mining and Metals - ICMM)។

## ៣. ការពិគ្រោះយោបល់

ការរៀបចំគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ត្រូវមានការសិក្សា និងពិគ្រោះយោបល់ត្រឹមត្រូវជាមួយរដ្ឋអំណាចមូលដ្ឋានដែលពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាដែលចាំបាច់ ដើម្បីធានាភាពសមស្របជាមួយលក្ខណៈសេដ្ឋកិច្ចសង្គម និងផលប្រយោជន៍នៅមូលដ្ឋានដែលគម្រោងផែនការអាជីវកម្មនឹងត្រូវអនុវត្ត។

## ៤. ឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ គឺជាឯកសារសាធារណៈ

ឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ដែលបានដាក់ស្នើសុំមកក្រសួងរ៉ែនិងថាមពល គឺជាឯកសារសាធារណៈដែលអាចដាក់ជូនឲ្យសាធារណជនទូទៅពិនិត្យបានតាមការស្នើសុំ។ ប្រសិនបើមានព័ត៌មានសម្ងាត់ អ្នកដាក់ពាក្យស្នើសុំត្រូវរៀបចំចងក្រងព័ត៌មានសម្ងាត់ទាំងនោះ ក្នុងឯកសារដោយឡែក ជាឧបសម្ព័ន្ធនៃឯកសារគម្រោងផែនការអាជីវកម្ម និងមានបញ្ជាក់ថាជាព័ត៌មានសម្ងាត់។ អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់អំពីការតម្រូវឲ្យរក្សាព័ត៌មានសម្ងាត់ទាំងនេះ។

## ៥. ការពិនិត្យវាយតម្លៃលើឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់

ឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ នឹងត្រូវពិនិត្យវាយតម្លៃដោយនាយកដ្ឋានជំនាញពាក់ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល តាមជំហានដូចខាងក្រោម៖

(ក) ពិនិត្យបឋមលើភាពអនុលោមស្របតាមសារាចរនេះ ហើយប្រសិនបើពុំមានភាពអនុលោមស្របតាមសារាចរនេះទេ ឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់នឹងត្រូវចុះបញ្ជីថាជា "សេចក្តីព្រាង" រួចត្រូវបញ្ជូនត្រឡប់ឲ្យអ្នកដាក់ពាក្យស្នើសុំវិញ។ ក្នុងករណីមានភាពអនុលោម ឯកសារនឹងត្រូវចុះបញ្ជីទទួលពាក្យសម្រាប់ការពិនិត្យវាយតម្លៃលម្អិតជាបន្ត។

(ខ) នៅពេលឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ត្រូវចុះបញ្ជីទទួលពាក្យសម្រាប់ការពិនិត្យវាយតម្លៃលម្អិតជាបន្ត នាយកដ្ឋានជំនាញពាក់ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពលនឹងអញ្ជើញអ្នកដាក់ពាក្យស្នើសុំ និងជំនាញការពាក់ព័ន្ធរបស់ខ្លួនដើម្បីមកបំភ្លឺបញ្ហាបច្ចេកទេសនានានៅក្នុងគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ដែលបានស្នើឡើង។ ក្នុងករណីចាំបាច់ នាយកដ្ឋានពាក់ព័ន្ធនឹងចាត់មន្ត្រីជំនាញ ចុះពិនិត្យវាយតម្លៃដល់ទីតាំងផ្ទាល់បន្ថែមទៀត។

(គ) ក្នុងការពិនិត្យវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចសង្គម នៃគម្រោងផែនការអាជីវកម្មរ៉ែសំណង់ នាយកដ្ឋានពាក់ព័ន្ធអាចធ្វើការពិគ្រោះយោបល់ជាមួយគ្រប់ភាគី អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធនានា តាមការចាំបាច់។

(ឃ) ក្នុងករណីមានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាននានា អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ជាមុន ដោយភ្ជាប់ជាមួយឯកសារគម្រោងផែនការអាជីវកម្មនូវលិខិតអនុញ្ញាត អាជ្ញាបណ្ណ កិច្ចព្រមព្រៀង ឬ ការអនុម័តឯកភាពរបស់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមបញ្ញត្តិតម្រូវនៃច្បាប់។

(ង) ក្រោយការពិនិត្យគ្រប់ជ្រុងជ្រោយ លើគ្រប់ទិដ្ឋភាព នៃគម្រោងផែនការអាជីវកម្មដែលបានស្នើឡើង នាយកដ្ឋានជំនាញពាក់ព័ន្ធនឹងធ្វើរបាយការណ៍ពីការពិនិត្យវាយតម្លៃ និងលើកមតិជូនរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ដើម្បីពិនិត្យនិងសម្រេច។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល អាចសម្រេចផ្តល់ ឬ មិនផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ដោយផ្អែកលើលទ្ធភាពសេដ្ឋកិច្ចសង្គមនៃគម្រោងអាជីវកម្មរ៉ែសំណង់ដែលស្នើឡើង។ ដោយយោងលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល អាចសម្រេចដូចខាងក្រោមចំពោះគម្រោងអាជីវកម្មដែលត្រូវបានបញ្ជាក់ច្បាស់លាស់ថា មានលក្ខណៈសេដ្ឋកិច្ចសង្គមល្អប្រសើរ ស្របតាមគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់រាជរដ្ឋាភិបាល៖

- ផ្តល់លិខិតឯកភាពជាគោលការណ៍ និងអនុញ្ញាតរយៈពេលសមស្របមួយ ដើម្បីអ្នកដាក់ពាក្យស្នើសុំធ្វើការបំពេញបែបបទ និងនីតិវិធីបន្ថែមស្របតាមច្បាប់ដូចជា ការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ការទទួលបានលិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណនានាតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន មុននឹងការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ឬ
- ផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំ បានអនុលោមបានត្រឹមត្រូវស្របច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងបានទទួលលិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណផ្សេងៗទៀត តាមការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានរួចហើយ។

## ៦. មាតិកា និងទម្រង់នៃឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់

មាតិកានៃឯកសារគម្រោងអាជីវកម្មរ៉ែសំណង់ស្របតាមសារាចរនេះ ត្រូវមានជាអប្បបរមានូវព័ត៌មាន និងទម្រង់ស្របតាមការកំណត់ក្នុងសារាចរនេះ។ ទម្រង់ និងភាពលម្អិតនៃព័ត៌មាននានា អាចត្រូវបានចងក្រង អាស្រ័យតាមស្ថានភាព និងលក្ខណៈដោយឡែកនៃជម្រករ៉ែសំណង់នីមួយៗ ប្រភេទរ៉ែ ឬបច្ចេកទេសអាជីវកម្មរ៉ែសំណង់ និងប្រតិបត្តិការពាក់ព័ន្ធ។

អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណរ៉ែសំណង់ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពល ចាប់តាំងពីដំណាក់កាលដំបូងនៃការរៀបចំឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់ ដើម្បីសម្រួលដល់ការជានាភាពអនុលោម និងឆ្លើយតបបានល្អប្រសើរចំពោះតម្រូវការព័ត៌មាននានាក្នុងការពិនិត្យវាយតម្លៃឯកសារគម្រោងផែនការអាជីវកម្មរ៉ែសំណង់។

មាតិកាសំខាន់ៗដែលត្រូវមានជាចាំបាច់ក្នុងឯកសារគម្រោងផែនការអាជីវកម្មធនធានរ៉ែ មានដូចខាងក្រោម៖

៦.១. ទំព័រក្របមុខ

លើទំព័រក្របមុខត្រូវមានព័ត៌មានដូចតទៅ៖

- ចំណងជើង
- ឈ្មោះទីតាំងគម្រោងអាជីវកម្ម និងប្រតិបត្តិការរ៉ែសំណង់
- លេខយោងអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ឬ កិច្ចព្រមព្រៀងអាជីវកម្មរ៉ែសំណង់ (បើមាន)
- ឈ្មោះអ្នកស្នើសុំ
- កាលបរិច្ឆេទ

៦.២. ទំព័រសង្ខេបកិច្ចសន្យាអនុវត្តកាតព្វកិច្ចបរិស្ថាន និងសង្គម

ការបញ្ជាក់ ឬ តារាងរៀបរាប់អំពី៖

- សង្ខេបខ្លឹមសារនៃផលប៉ះពាល់បរិស្ថាន និងសង្គមសំខាន់ៗ និងគម្រោងផែនការគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់ទាំងនោះ។
- សង្ខេបវិធានការណ៍គ្រប់គ្រង ត្រួតពិនិត្យ និងកិច្ចសន្យាស្តា និងកែលម្អបរិស្ថានឡើងវិញ។

៦.៣. ព័ត៌មានទូទៅ

៦.៣.១. ព័ត៌មានអត្តសញ្ញាណ និងទំនាក់ទំនងរបស់អ្នកស្នើសុំ

៦.៣.២. គោលដៅនៃគម្រោងផែនការអាជីវកម្ម

៦.៣.៣. ទីតាំង និងផែនទីគំនូសប្លង់ទីតាំងប្រតិបត្តិការផ្សេងៗ (Site Layout Plan)

៦.៣.៤. ប្រវត្តិប្រតិបត្តិការរ៉ែសំណង់ពីមុន ឬបទពិសោធន៍របស់ជំនាញការសំខាន់ៗ

៦.៣.៥. ទិព្វសម្ភារៈប្រតិបត្តិការរ៉ែសំណង់មានស្រាប់ និងស្ថានភាពអាជីវកម្មក្នុងពេលបច្ចុប្បន្ន

៦.៤. ស្ថានភាពបរិស្ថាន និងសង្គម

៦.៤.១. សង្ខេបលក្ខណៈភូគព្ភសាស្ត្រតំបន់

៦.៤.២. សង្ខេបលក្ខណៈភូគព្ភសាស្ត្រនៅទីតាំងនៃគម្រោងអាជីវកម្ម

៦.៤.៣. លក្ខណៈស្រទាប់ដី

៦.៤.៤. លក្ខណៈប្រព័ន្ធផ្លូវទឹកលើដី និងក្រោមដី

៦.៤.៥. ប្រភេទរុក្ខជាតិ និងជីវចម្រុះក្នុង និងជុំវិញតំបន់គម្រោងអាជីវកម្ម

៦.៤.៦. ស្ថានភាពបរិស្ថានសង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌

៦.៥. ព័ត៌មានអំពីគម្រោងអាជីវកម្ម

៦.៥.១. តារាងអំពីផ្ទៃដី និងទំហំប៉ះពាល់ដោយប្រតិបត្តិការរ៉ែសំណង់
៦.៥.២. ប្រភេទ និងសកម្មភាពប្រតិបត្តិការរ៉ែសំណង់
៦.៥.៣. បច្ចេកទេស និងខ្សែសង្វាក់ផលិតកម្ម និងទំហំផលិតកម្ម
៦.៥.៤. ការស្តុកទុក និងការទុកដាក់គំនររ៉ែផ្សេងៗ
៦.៥.៥. ការបញ្ចេញចោល ឬ ការទុកដាក់សំណល់ផ្សេងៗ
៦.៥.៦. ហេដ្ឋារចនាសម្ព័ន្ធប្រតិបត្តិការរ៉ែសំណង់ និងគ្រឿងចក្រ
៦.៥.៧. ការប្រើប្រាស់កំលាំងពលកម្ម និងជំនាញការ
៦.៥.៨. ការដឹកជញ្ជូន និងពាណិជ្ជកម្ម
៦.៥.៩. តម្រូវការ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
៦.៥.១០. លិខិតបទដ្ឋានគតិយុត្តិ និងតម្រូវការភាពអនុលោមផ្សេងៗ
៦.៦. ព័ត៌មានសង្ខេបអំពីផែនការគ្រប់គ្រង និងការការពារបរិស្ថាន
៦.៦.១. ការកាប់ឆ្ការទន្រ្ទានព្រៃ
៦.៦.២. ការការពារប្រព័ន្ធផ្លូវទឹក
៦.៦.៣. ការការពាររុក្ខជាតិ និងជីវចម្រុះ
៦.៦.៤. ការការពារការហូរច្រោះស្រទាប់ដី និងដីជាតិ
៦.៦.៥. ការគ្រប់គ្រងសំណល់នៅក្នុងការដ្ឋាន និងប្រតិបត្តិការរ៉ែសំណង់
៦.៦.៦. ការគ្រប់គ្រងសារធាតុមានហានិភ័យ
៦.៦.៧. ការការពារការបំពុលបរិយាកាស និងសម្លេង
៦.៦.៨. វិធានការសុខភាព និងសុវត្ថិភាពការងារក្នុងការដ្ឋាន
៦.៦.៩. វិធានការការពារសុវត្ថិភាពសាធារណៈ
៦.៧. ការការពារផលប៉ះពាល់សង្គម និងជំរុញអភិវឌ្ឍសហគមន៍មូលដ្ឋាន
៦.៧.១. ការការពារទីតាំងវប្បធម៌ ប្រវត្តិសាស្រ្ត ឬ ទីសក្ការៈផ្សេងៗ
៦.៧.២. ការការពារ និងលើកកំពស់សកម្មភាពសេដ្ឋកិច្ចមូលដ្ឋាន និងតំបន់អេកូទេសចរណ៍
៦.៧.៣. ការការពារ និងដោះស្រាយទំនាស់លើការប្រើប្រាស់ដីធ្លីជាមួយ សហគមន៍មូលដ្ឋាន
៦.៧.៤. គម្រោងកម្មវិធីទទួលខុសត្រូវសង្គមរបស់សាជីវកម្ម និងការចូលរួមអភិវឌ្ឍន៍ សហគមន៍
៦.៨. គម្រោងស្តារបរិស្ថានឡើងវិញក្រោយការបិទការដ្ឋាន
៦.៨.១. ការប្រើប្រាស់ដី និងការដ្ឋានផ្សេងៗ
៦.៨.២. ផែនការស្តារឡើងវិញ
៦.៨.៣. វិធីសាស្រ្ត និងកម្មវិធីការងារត្រូវអនុវត្ត
៦.៨.៤. គម្រោងប៉ាន់ស្មានថវិកាសម្រាប់ការអនុវត្តន៍ការស្តារបរិស្ថានឡើងវិញ
៦.៩. វិធានការស្តីពីសុវត្ថិភាព
៦.៩.១. គោលការណ៍សុវត្ថិភាពសំខាន់ៗ
៦.៩.២. វិធានការសុវត្ថិភាពក្នុងប្រតិបត្តិការ

៦.៩.៣. ការគ្រប់គ្រង និងវិធានការក្នុងពេលមានអាសន្ន

៦.៩.៤. ការស៊ើបអង្កេត និងរាយការណ៍អំពីគ្រោះថ្នាក់ផ្សេងៗក្នុងករណីកើតឡើង

៦.១០. ការសិក្សាសមិទ្ធិសេដ្ឋកិច្ច

៦.១០.១. ការប៉ាន់ស្មានអំពីទុនវិនិយោគ

៦.១០.២. ការប៉ាន់ស្មានអំពីចំណាយប្រតិបត្តិការ

៦.១០.៣. ការប៉ាន់ស្មានចំណាយបញ្ចប់ការដ្ឋាន និងស្តារបរិស្ថានឡើងវិញ

៦.១០.៤. ការប៉ាន់ស្មានលទ្ធភាពសេដ្ឋកិច្ច និងការបង់ពន្ធដារ និងសួយសារអាករ

## ៧. បញ្ជីឯកសារយោង និងឧបសម្ព័ន្ធផ្សេងៗ

ឯកសារគម្រោងអាជីវកម្មរ៉ែសំណង់ ត្រូវមានភ្ជាប់នូវឯកសារយោង និងឧបសម្ព័ន្ធផ្សេងៗតាមការចាំបាច់ ដើម្បីផ្តល់ព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ត្រឹមត្រូវសម្រាប់គោលបំណងវិនិច្ឆ័យលើ លក្ខណៈសេដ្ឋកិច្ចសង្គមនៃទម្រង់ប្រតិបត្តិការរ៉ែសំណង់ដែលស្នើឡើង។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរ៉ែនិងថាមពល ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងរ៉ែនិងថាមពលវិញ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន ពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ